# បុព្វកថា

បទអប់រំខ្លី ដែលចេញផ្សាយតាមបណ្តាញគេហទំព័រនេះ បំផុសផ្តួចផ្តើមគោលគំនិតឡើងដោយ ព្រះមហាធម្មាលង្ការពោ ចាន់ សុជន គឺជាកម្រងទស្សនៈប្រកបដោយវប្បធម៌ពហុគំនិតច្រើនវិស័យ ក្នុងនោះបានផ្តោតជាសំខាន់ទៅលើ លទ្ធិសាសនា វប្បធម៌ ទំនៀមទម្លាប់ ប្រពៃណីសង្គមសាស្ត្រ ចិត្តសាស្ត្រ វិទ្យាសាស្ត្រ បញ្ហាជីវិតរួមទាំងដំបូន្មាន និងទ្រឹស្តីបទក្នុងបុរាណសម័យនិងបច្ចុប្បន្នសម័យ។ គ្រប់បរិបទនីមួយៗ យើងដែលជាអ្នកស្រាវជ្រាវចងក្រងពុំមានចេតនាប្រតិដ្ឋ ឬក៏បំភ្លៃឲ្យឃ្លាតក្លាយជ្រុលជ្រួសហួសខូចតម្លៃច្បាប់ដើមឡើយ គ្រាន់តែបំពេញសម្រួលបន្ថែមខ្លះៗ ដូចជាការវិភាគ ការពន្យល់ គំនិតពិចារណាបំណិននិងគតិសាស្ត្រប្លែកៗ ដើម្បីសំយោគអមនិងឲ្យចូលទៅជួយចិញ្ចឹមបំប៉ននូវផ្នែកនៃអត្ថបទដើម ឲ្យកាន់តែស៊ី

ជម្រៅ និងមានភាពរស់រវើកពោរពេញដោយអត្ថរសអត្ថន័យ និងប្រព័ន្ធអក្ខរក្រមត្រឹមត្រូវស្របតាមសម័យកាលតែប៉ុណ្ណោះ ។

មួយវិញទៀត បទអប់រំខ្ញីនេះ នឹងបានជាមាគ៌ាគតិដ៏យ៉ាងវិសេសវិសាល សម្រាប់ណែនាំបណ្ដុះពន្លូតសតិសម្បជញ្ញៈរបស់ សិស្ស និស្សិត យុវជន កុលបុត្រកុលធីតា ឲ្យក្លាយជាអ្នកមានយោនិសោមនសិការយល់ដឹងខ្ពង់ខ្ពស់ទាំងខាងផ្នែកសង្គម ទាំងខាងផ្នែកសាសនាប្រកបទៅដោយបញ្ញានុកូលភាព ។

យើងសង្ឃឹមថា គ្រប់អត្ថបទដែលបានផ្សាយចេញទៅនេះ នឹងបានជាសារប្រយោជន៍ធំធេងចំពោះអ្នកចូលអានគ្រប់រូប ហើយជាពិសេសទៅទៀតនោះ នឹងបានកាត់បន្ថយនូវគម្លាតរវាងសាសនា និងសង្គមលោកឲ្យបានជាអតិបរមា ។

នៅទីបំផុត ក្រុមការងារយើងសូមអភ័យទោសប្រសិនបើកម្រងអត្ថបទទាំងអម្បាលម៉ាននេះ មានភាពផ្គាំផ្គងត្រង់ផ្នែកណាមួយនោះ សូមអស់លោកអ្នកអាន

អ្នកសិក្សាទាំងឡាយ មេត្តាផ្តល់ដំណឹងមកក្រុមការងារយើងឬជួយកែតម្រូវដោយអនុគ្រោះផងចុះ។ ក្រុមការងារយើងរង់ចាំទទួលមតិឬអនុសាសន៍គ្រប់យ៉ាង មិនថាអនុសាសន៍នោះ ជាការរិះគន់ឬក៏សរសើរទេ គឺសុទ្ធតែជាប្រទីបសម្រាប់ទ្រោលបំភ្លឺ នាំទៅរកការសម្រេចការងារទាំងអស់ ។

"និធីនំ ៗ បវត្តារំ=អ្នកពោលប្រាប់នូវទោសកំហុសការផ្តាំផ្តួងទុកដូចជាពោលប្រាប់នូវកំណប់ទ្រព្យ" ។

សូមកល្យាណមិត្តទាំងអស់ ទទួលបាននូវសេចក្តីសុខ និងភាពជោគជ័យគ្រប់ភារកិច្ច កុំបីក្លាយទៅជាបការៈដទៃឡើយ ៕

ធ្វើនៅវត្តប្រាសាទស្រះកណ្តាល(ខ្វាស់)ថ្ងៃអង្គារ ៨កើត ខែពិសាខ ព.ស២៥៥៧ ទី៦ ខែឧសភា ឆ្នាំ២០១៤

# រចនាសម្ព័ន្ធ
# នៃរចនាការកម្រង័បងអប់រំទ្វី



១. ព្រះមហា ធម្មាលង្កាពោ ចាន់ សុជន



២. ព្រះភិក្ខុ មុនិប្បមោ ជឿន សុជាតិ



៣. ព្រះភិក្ខុ តសន្ទចិត្តោ វង្ស វិចិត្រ



៤. ភិក្ខុ ធម្មមុនី ជា ពុទ្ធី

៥.  ព្រះឧទ្ទេសាចារ្យ អគ្គសិរីវិមលញ្ញាណ លី ប៊ុន លីន

៦.  ឧទ្ទេសាចារ្យ សួន សិរី

៧.  ផ្នែកការីកុំព្យូទ័រ ចាន់ សុជិន(កោរ)

# បឋមអប់រំទី

## ស្តីអំពី: បុព្វភាគនៃព្រះពុទ្ធសាសនា

*សំណួរ: តើព្រះពុទ្ធសាសនាជាអ្វី?*

*ពាក្យប្រៀនប្រដៅអប់រំទូន្មាន របស់ព្រះសម្ពុទ្ធទាំងឡាយ ឈ្មោះថាព្រះពុទ្ធសាសនា ដែលប្រែថាច្បាប់, ថាធម្មជាតិ, ថាសភាវៈទ្រទ្រង់លោក...។*

*ដែលប្រែថា ច្បាប់ គឺជាកន្សោមក្រឹត្យក្រមនៃបទបញ្ញត្តិ បទអនុញ្ញាត និងបទអភិសមាចារ ដែលព្រះពុទ្ធគ្រប់ព្រះអង្គទ្រង់ត្រាស់អនុម័តទុកចំពោះបព្វជិត និងបរិសទ្យគោរពត្រង់ត្រាប់ ។ ចំណែកខាង ច្បាប់ប្រទេសសម្រាប់មនុស្សជាតិវិញ ដែលសភាតាក់តែងអនុម័តមកក៏ត្រូវទាមទារឲ្យសមស្របតាមគន្លងព្រះធម៌ ដែលជាច្បាប់នេះដែរ ពីព្រោះថា បើវតលប្រាសចាកឃ្លាតចេញពីព្រះធម៌ហើយ ពុំមានសុក្រឹតភាពឬសុចរិតភាពអាចវិនិច្ឆ័យរកយុត្តិធម៌ឬអយុត្តិធម៌បានឡើយ ។*

*ដែលប្រែយកបានថា ធម្មជាតិនោះ គឺជាសភាវៈ*

កើតឡើងជាធម្មតាទៅតាមហេតុបច្ច័យនៃរូបធាតុ ប្រកបដោយលក្ខណៈជាជីវសាស្ត្រ ភូគព្ភសាស្ត្រ និងសភាវៈសាស្ត្រ រួមមានមនុស្ស សត្វ រុក្ខជាតិ ទឹក ដី ភ្លើង ខ្យល់ ភ្នំ សមុទ្ទ សកល និង លោកធាតុជាដើម។ បញ្ហានៃធម្មជាតិទាំងនេះ ព្រះពុទ្ធសាសនាបានបើកបង្ហាញនូវរបកគំឃើញ (ញេយ្យធម៌) នៅក្នុងកំណកំណើតវិវឌ្ឍន៍សំយោគរវាងហេតុបច្ច័យយ៉ាងច្បាស់លាស់ ធ្វើឲ្យមនុស្សយល់ដឹងនូវសភាវៈពិតដ៏ចាំបាច់បំផុត ចំពោះជីវិត រូបកាយ និងជាតិកំណើតរបស់ខ្លួននិងវត្ថុធាតុនៅជុំវិញខ្លួន។ ឯពួកវិទ្យាករទាំងឡាយក្នុងលោក មានអ្នកវិទ្យាសាស្ត្រជាដើម ដែលសិក្សាយល់ចេះដឹងចូលចិត្តទៅបានក្នុងផ្នែកធម្មជាតិសាស្ត្ររហូតដល់ទៅទាញយកផលប្រយោជន៍ពីធម្មជាតិមកផលិតបង្កើតជាឧបករណ៍ឬវត្ថុសម្ភារៈទំនើបៗនោះ សុទ្ធតែសិក្សាវិភាគប្រកបដោយភាពស៊ីជម្រៅយ៉ាងជាក់លាក់ទៅលើសម្ពន្ធភាពនៃធម្មជាតិ មានម៉ាស អាតូម វ៉ាឡង់ និងម៉ូលេគុលជាដើម តាមលំនាំក្រឹត្យក្រមនៃព្រះធម៌ជាធម្មជាតិនេះឯង, បើបែរជាមិនបានសិក្សាត្រិះរិះស្រាវជ្រាវរាវឲ្យឃើញនូវគ្រប

ខ័ណ្ឌហេតុបច្ច័យដែលបង្កើតធម្មជាតិទេនោះ ក៏ពុំអាចនឹង រចនារូបមន្ត ក្បួនខ្នាតកម្មសិក្សា ឧបករណ៍ប្រើប្រាស់ មានលក្ខខណ្ឌគួរឲ្យកត់សម្គាល់ជឿទុកចិត្តបានឡើយ ។

ដែលប្រែថា សភាវៈទ្រទ្រង់លោក គឺព្រះពុទ្ធសាសនា ប្រកបដោយកម្មវិបាកសាស្ត្រ ប្រាប់បង្ហាញណែនាំពន្យល់ពី មូលហេតុនៃសុខ ទុក្ខ អំពើល្អ អំពើអាក្រក់ ពោលគឺប្រាប់ ពីដំណើរសេកម្មភាពរបស់សត្វលោក ដែលជាហេតុនាំឲ្យ ចម្រើនវិនាសក្នុងលោកនេះ ក្នុងបរលោក និងក្នុង ព្រះនិព្វាន។

សរុបសំយោគទស្សនន័យទៅ ពុទ្ធសាសនា ជាទ្រឹស្តី លោក គឺជាជាទ្រឹស្តីបទនៃព្រះពុទ្ធជាម្ចាស់ដែលឆ្លុះបញ្ចាំង ជាសកលនូវអត្ថៈ(វឌ្ឍនភាព) និងអនត្ថៈ(មហន្តរាយភាព) ចំពោះពិភពលោកគ្រប់កាលៈទេសៈ។ ជាក់ស្តែង ពិភព លោកយើងនេះ ចាប់វិវឌ្ឍកកើតឡើងនៅពេលណា ពុទ្ធ-សាសនាជាទ្រឹស្តីលោកក៏ចាប់កកើតឡើងនៅពេលនោះដែរ ព្រោះថា គ្រប់សភាវៈទាំងនោះមានសម្ព័ន្ធភាពជាប់ទាក់ទង ក្នុងមជ្ឈដ្ឋានទ្រឹស្តីលោកសុទ្ធសាធ និងប្រកបដោយហេតុ

បច្ច័យពេញលេញ។ តាំងពីបុរាណកាលមកទល់នឹងបច្ចុប្បន្នកាល ប្រជាជនក្នុងពិភពលោកតែងចេះដឹងយល់ស្គាល់នូវទស្សនៈ បច្ចេកទេស សីលធម៌ អរិយធម៌ វឌ្ឍនធម៌ ឃ្លាំងក្បួនខ្នាតទូទៅ ការអប់រំ ផ្លូវសុខសន្តិភាព ពីឪពុកម្តាយ គ្រូអាចារ្យឬបុព្វបុរសហើយជនទាំងនោះសោត សុទ្ធតែបានចេះចាំតៗគ្នាមកទៀត នូវគម្រងធម្មជាតុពីព្រឹទ្ធាចារ្យបុរាណាចារ្យនិងបុព្វបុរស...។ ឯបុព្វជនទាំងអស់នោះទៀតសោត ត្រូវជាសាសនិកសាច់សាលោហិតនៃព្រះពុទ្ធ-សាសនា ជាទ្រឹស្តីលោកបានសិក្សាចេះចាំនូវសភាវធម៌ទាំងនោះ ពីមនុស្សអ្នកប្រាជ្ញជំនាន់មុនៗដរាបរៀងគ្នាមកទៀត ដូចគ្នានឹងមនុស្សទំនាន់នេះដែរ តែងសិក្សាចេះដឹងអ្វីៗ ដែលមានក្នុងលោកនេះតៗគ្នា ជាលំដាប់តាមកាលវិវឌ្ឍន៍ ។

ហេតុដូច្នេះ បច្ចាជនក្នុងពិភពលោកទាំងអស់ គឺសុទ្ធសឹងជាពន្ធុវង្ស(ផៅពង្សសន្តាន) នៃពុទ្ធសាសនា តែមានមនុស្សភាគច្រើនលើសលប់ ជាបុគ្គលទុទិដ្ឋិនិយមមិនបានតាំងខ្លួនជាពន្ធុវង្សឡើយហើយគិតថា ការដែលខ្លួន

ចេះដឹងនូវផ្នែកទស្សនៈ ធម្មជាតុ បច្ចេកទេស សីលធម៌ ជាដើម គឺចេះឡើងឯងៗ ឬចេះពីលទ្ធិ គ្រូ សាស្ត្រាចារ្យ ឬថាចេះពីរូបមន្តក្បួនខ្នាតនៃបុព្វជនខ្លួនទៅវិញ ឥតដឹងថា ប្រព័ន្ធធម្មសភាវៈនោះ ជារបស់ព្រះពុទ្ធសាសនាសោះឡើយ។ មានពួកជនមួយចំនួនទៀត មិនត្រឹមតែមិនតាំងខ្លួនជាអ្នកដឹងគុណពុទ្ធសាសនាទេ ថែមទាំងប្រកាសតាំងខ្លួនជាគូសត្រូវ ជាគូប្រឆាំងនឹងព្រះពុទ្ធសាសនា ជាគ្រូដើម ជារូបមន្តក្បួនច្បាប់ដើមថែមទៀត៕

(ដកស្រង់សម្រួលពីអត្ថបទព្រះសិទ្ធត្ថោ សុដ ស៊ីវ ដោយ អគ្គសិរីវិមលញ្ញាណ លី ប៊ុន លីង)